FEBRUARY-MARCH 2009
Nº 15

CAMBODIA INTERNATIONAL AIRPORTS

# airportsfocus

## អារម្ភកថា

នៅក្នុងស្ថានភាពឆ្នាំនេះខណៈពេលដែលរបាយការណ៍ទាំងអស់បានប្រមូលចងក្រងវិភាគ យើងបានដឹងច្បាស់ថា តើយើងបានទទួលលទ្ធផលដូចម្តេចនៅឆ្នាំ២០០៨កន្លងទៅនេះ។ ចំណុចសំខាន់សំរាប់យើងត្រូវយកពេលវេលាក្នុងការសំលឹងមើលពីរយៈពេលកន្លងទៅនេះដើម្បីយើងត្រៀមលក្ខណៈសម្បត្តិជាមុនសំរាប់ឆ្នាំខាងមុខនេះ។

ចំនួនអ្នកដំណើរឆ្លងកាត់តាមអាកាសយានដ្ឋានអន្តរជាតិភ្នំពេញនិងសៀមរាបបានធ្លាក់ចុះបន្ទាប់ពីកំណើនអ្នកដំណើរបានស្ថិតក្នុងដំណាក់កាលដ៏យូរ។

ចំណែកនៅឃ្លាំងទំនិញអាកាសយានដ្ឋានអន្តរជាតិភ្នំពេញក៏មានសភាពដូចខាងលើនេះដែរ។ អស់លោកបានដឹងហើយថាអ្នកម៉ៅការរបស់យើងមួយភាគធំបានរងផលប៉ះពាល់ពីវិបត្តិសេដ្ឋកិច្ចពិភពលោក ហើយវិបត្តិនេះបានជះឥទ្ធិពលទៅដល់តំរូវការរបស់ក្រុមហ៊ុនអាកាសចរណ៍។

វិបត្តិនេះវាអូសបន្លាយពេលវេលាគ្មានកាលកំណត់បណ្តាលអោយប្រជាពលរដ្ឋអោយមានការប្រយ័ត្នប្រយែងក្នុងការសន្សំសំចៃនិងកាត់បន្ថយការចំណាយ ។វិបត្តិសេដ្ឋកិច្ចខាងលើនេះបានធ្វើអោយបណ្តាអាកាសយានដ្ឋាននៅលើពិភពលោកបានទទួលរងគ្រោះហើយយើងក៏ទទួលរងគ្រោះដូចគេដែរប៉ុន្តែក្រុមហ៊ុនយើងមានលទ្ធភាពទប់ទល់នឹងវិបត្តិនេះនោះអាស្រ័យទៅលើថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់ដែលបានបំពេញការងារស្មោះស្ម័គ្រនិងប្រកបដោយសមត្ថភាពដែលជាការរួមចំណែកកសាង ការពារសង្គ្រោះបរិយាកាសការងារសំរាប់ជាគុណប្រយោជន៏ចំពោះយើងគ្រប់ៗគ្នា។ ជាមួយគ្នានេះដែរយើងមិនត្រូវអស់សង្ឃឹមទៅនឹងការធ្លាក់ចុះនៃប្រភពចំណូលរបស់យើងហើយនឹងកំពុងបន្តធ្លាក់ចុះដោយសារតែវិបត្តិសេដ្ឋកិច្ចពិភពលោកនោះទេ។

ជាសំណាងល្អក្រុមហ៊ុនអាចជួយគាំទ្រនិរន្តភាពចំពោះការផ្គត់ផ្គង់ជីវភាពមានដូចជា: ការដំឡើងប្រាក់បៀវត្សដល់បុគ្គលិកដែលពួកគេត្រូវការចាំបាច់សំរាប់ជីវភាពប្រចាំថ្ងៃដែលប្រឈមនឹងទំនិញឡើងថ្លៃ។

ស្ថិតនៅក្នុងចំណោមនៃបរិយាកាសមិនអនុគ្រោះបែបនេះក្រុមហ៊ុនយើងប្រហែលជាក្រុមហ៊ុនតែមួយនៅកម្ពុជាដែលអាចទប់ទល់នឹងវិបត្តិដ៏ធំនេះជាមូលដ្ឋាន ។ទោះជាយ៉ាងណាក៏ដោយខ្ញុំសូមធ្វើការបញ្ជាក់ជូនដូចខាងដើមថាយើងត្រូវប្រុងប្រៀបខ្លួនជាមួយនឹងបរិយាកាសមិនអនុគ្រោះដ៏យូរអង្វែងហើយដើម្បីនឹងទ្រទ្រង់និរន្តភាពរបស់យើង។ យើងគួរសួរខ្លួនឯងថាក្រុមហ៊ុនយើងបានជួយនៅក្នុងស្ថានភាពបែបនេះក៏ប៉ុន្តែថាតើយើងអាចធ្វើអ្វីខ្លះដើម្បីជួយក្រុមហ៊ុនវិញ។

អ្វីដែលជាការសំរេចជោគជ័យបានដោយងាយនោះគឺជាការប្រតិបត្តិរបស់យើងដូចចំណុចខាងក្រោមនេះគ្រប់ៗគ្នាហើយនៅគ្រាបញ្ចប់វានឹងផ្តល់ផលប្រយោជន៏ចំពោះយើងគ្រប់គ្នាក្នុងនោះមានដូចជា:





*អ្នកដំណើរមានចំនួនតិចតួចបានធ្វើដំណើរឆ្លងកាត់អាកាសយានដ្ឋានអន្តរជាតិភ្នំពេញក្នុងពេលមានវិបត្តិសេដ្ឋកិច្ចពិភពលោក*

- ជៀសវាងការខ្ជះខ្ជាយនិង មានស្មារតីសន្សំសំចៃពីគ្រប់សមាសភាពទាំងអស់នៅនឹងកន្លែងបំពេញការងារប្រចាំថ្ងៃ(ទោះជាបន្តិចបន្តួចយ៉ាងណាក៏ដោយ)ត្រូវពិចារណាថាអស់លោកចេះសន្សំបែបណានៅលំនៅដ្ឋានហើយត្រូវអនុវត្តរបៀបនេះនៅនឹងកន្លែងបំពេញការងារ។
- ត្រូវមានស្មារតីកចិត្តទុកដាក់ចំពោះភ្ញៀវ អតិថិជន អ្នករួមការងារដៃគូរនិងសហការីរបស់យើង (ចេះជួយគ្នាទៅវិញទៅមក)ចេះគិតយកចិត្តទុកដាក់អោយបានច្រើនពីសហប្រតិបត្តិការនិងចេះដោះស្រាយបញ្ហាដូចដែលអស់លោកមានទំនាក់ទំនងជាមួយអតិថិជនដែលធ្លាប់បានទទួលការយកចិត្តទុកដាក់។
- គ្រប់ៗគ្នាត្រូវខិតខំបំពេញការងារនៅក្នុងក្រុមហ៊ុនរបស់យើងអោយកាន់តែប្រសើរឡើងថែមទៀតហើយគ្រប់ៗគ្នាអាចចូលរួមបំពេញការងារនេះតាមមុខជំនាញរៀងៗខ្លួន។

នាពេលអនាគតខាងមុខក្រុមហ៊ុនរបស់យើងមានជិវិតរស់រានអាស្រ័យនៅលើសមត្ថភាពរបស់យើងគ្រប់គ្នាដែលត្រូវកែលំអរពីទំលាប់ការងារប្រចាំថ្ងៃរបស់យើង ។ខ្ញុំសូមធ្វើការជឿជាក់នៅលើអ្នកគ្រប់គ្នាដែលបំពេញការងារទៅតាមគំរោងដូចបានគ្រោងទុក។

*លោក* ***នីកូឡា ដឺវឺឡឺ***
*អគ្គនាយកក្រុមហ៊ុនសម្បទាន*
*ព្រលានយន្តហោះ SCA និង CAMS*

# ក្រុមពន្លត់អគ្គីភ័យអាកាសយានដ្ឋានអន្តរជាតិសៀមរាបឆ្លើយតបការហ្វឹកហាត់ទាន់ពេលវេលា



ក្រុមពន្លត់អគ្គីភ័យអាកាសយានដ្ឋានអន្តរជាតិសៀមរាបបានបញ្ចេញសកម្មភាពយ៉ាងស្រួចស្រាវហ្វឹកហាត់លំហាត់

សញ្ញាអាសន្នកំរិតខ្ពស់មួយពីយន្តហោះមួយគ្រឿងកំពុងជួបប្រទះបញ្ហាក្នុងខណៈពេលចុះចតបានផ្តល់សញ្ញាពីបន្ទប់ត្រួតពិនិត្យចរាចរណ៏ដែនអាកាសទៅកាន់ក្រុមសង្គ្រោះនិងពន្លត់អគ្គីភ័យហើយគ្រោះថ្នាក់នេះបានកើតឡើងនៅក្នុងចំណុច Charlie One Four Grid Reference ។នេះគ្រាន់តែការចាប់ផ្តើមនៃការអនុវត្តលំហាត់សង្គ្រោះដែលបានចាប់ផ្តើមឡើងកាលពីថ្ងៃទី ២២ ខែមករាឆ្នាំ ២០០៩ នាវេលាម៉ោង ១១ និង ១៥ នាទី កន្លងទៅនេះនៅឯអាកាសយានដ្ឋានអន្តរជាតិសៀមរាប ។ រយៈពេលតែ១នាទីនិង៣០វិនាទីក្រោយការផ្តល់សញ្ញាអាសន្នរថយន្តដឹកនាំបញ្ជាបានមកដល់ទីតាំងកើតហេតុនិង១០វិនាទីក្រោយមកទៀតរថយន្តពន្លត់អគ្គីភ័យចំនួន ៤ គ្រឿងបានមកដល់ជាបន្តបន្ទាប់ហើយចាប់ផ្តើមប្រតិបត្តិការពន្លត់អគ្គីភ័យយ៉ាងសកម្ម និងរួសរាន់ជាទីបំផុត ។ រយៈពេល៤នាទីក្រុមសង្គ្រោះនិងពន្លត់អគ្គីភ័យបានគ្រប់គ្រងពន្លត់អគ្គីភ័យដោយជោគជ័យ ។បន្តមកទៀតក្រុមប្រតិបត្តិការសង្គ្រោះបានផ្តើមការងាររបស់ខ្លួនដោយមានកិច្ចគាំទ្រពីក្រុមពន្លត់អគ្គីភ័យបានរៀបចំឧបករណសំភារៈសង្គ្រោះនិងទីតាំងសុវត្ថិភាពរួចរាល់ជាស្ថាពរនៅម៉ោង១១ និង២២នាទី ។

កិច្ចប្រតិបត្តិការហ្វឹកហាត់សង្គ្រោះបានដំណើរការអស់រយៈពេល២៤នាទីហើយបានបញ្ចប់ការងារហ្វឹកហាត់នៅវេលាម៉ោង ១១ និង ៤០ នាទី ។ អង្គការអាកាសចរណ៏ស៊ីវិលអន្តរជាតិបានតំរូវអោយអាកាសយានដ្ឋានទាំងអស់ត្រូវប្រកាន់យកការត្រៀមខ្លួនប្រតិបត្តិការសំរាប់ការជួយសង្គ្រោះនិងប្រយុទ្ធប្រឆាំងពន្លត់អគ្គីភ័យក្នុងកំរិតខ្ពស់ ។ក្រុមពន្លត់អគ្គីភ័យត្រូវតែរៀបចំកន្លែងកើតហេតុផ្សេងៗគ្នាហើយក្នុងចំណោមពួកគេម្នាក់ៗត្រូវធ្វើរបាយការលំអិតអំពីផែនការគ្រោះអាសន្ននៅអាកាសយានដ្ឋាន ។ ទោះជាយ៉ាងណាមានគំរោងជារឿងមួយហើយនិងការផ្តល់លំអិតពីសេវាកម្មជារឿងមួយផ្សេងទៀតព្រោះថាគ្មានអ្នកណាម្នាក់អាចដឹងច្បាស់ពិតប្រាកដពីពេលវេលាដែលកើតមានគ្រោះថ្នាក់ថាតើមានអ្វីនឹងកើតឡើងហើយបញ្ហាចំពោះមុខគឺត្រូវរៀបចំឆ្លើយបទៅនឹងហេតុការណ៏កើតឡើងសំខាន់ជាងនេះទៀតសមាសភាពនៃក្រុមពន្លត់អគ្គីភ័យគឺជាអ្នកឆ្លើយតបទៅនឹងប្រតិបត្តិការពន្លត់អគ្គីភ័យ ។

ក្រុមពន្លត់អគ្គីភ័យត្រូវឆ្លើយតបក្នុងការធ្វើដំណើរអោយបានរហ័សទៅដល់ចុងផ្លូវរត់ចុះចតយន្តហោះក្នុងរយៈពេល២នាទីឯចំណុចទី២ពួកគេត្រូវពន្លត់អគ្គីភ័យអោយបានជាស្ថាពរនិងរៀបចំចាត់ចែងកន្លែងសុវត្ថិភាពសំរាប់ជនរងគ្រោះ ។

ថ្នាក់ដឹកនាំពីគ្រប់ផ្នែកនៅអាកាសយានដ្ឋានអន្តរជាតិសៀមរាប( ថ្នាក់គ្រប់គ្រងស្ថានីយ៏ការិយាល័យវិស្វកម្ម ការិយាល័យហិរញ្ញវត្ថុការិយាល័យប្រតិបត្តិការ ការិយាល័យពាណិជ្ជកម្ម និងការិយាល័យធនធានមនុស្សនិងរដ្ឋបាល) មានវត្តមានរួមជាមួយបណ្តាស្ថាប័នជាដៃគូរសហការនឹងអាកាសយានដ្ឋាន( រដ្ឋលេខាធិការដ្ឋានអាកាសចរណ៏ស៊ីវិលនាយកគ្រប់គ្រងអាកាសយានដ្ឋានកងរាជអាវុធហត្ថលើផ្ទៃប្រទេសនិងនគរបាលនៃខេត្តសៀមរាប) ។

លោក **Feliciano ENRIQUEZ**

*នាយកផ្នែកគ្រប់គ្រងសន្តិសុខ-សុវត្ថិភាព*

*អាកាសយានដ្ឋានអន្តរជាតិសៀមរាប*



# ពីជីវិតកុមារក្រីក្រមកជាបុគ្គលិកអាកាសយានដ្ឋាន....

មានសម្បុរខ្មៅស្រអែមភ្នែកតូចៗសក់ខ្លីស្ថិតនៅក្នុងវ័យ២៧ឆ្នាំនិងមានស្នាមញញឹមរាក់ទាក់បានរៀបរាប់ពីជីវិតផ្ទាល់ខ្លួននៅមុនពេលដែលបានចូលបំរើការងារនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញថារូបគេជាកូនទី២ក្នុងក្រុមគ្រួសារក្រីក្រដែលមានកូនចំនួន៤នាក់( ប្រុស១ ស្រី ៣ ) នេះជាការថ្លែងប្រាប់ដោយយុវជនឯម សារ៉ាត់ ។

បើទោះជាជីវភាពគ្រួសារពើបប្រទះនឹងការលំបាកផ្នែកជីវភាពយ៉ាងណាក៏ដោយសារ៉ាត់នៅតែប្រឹងប្រែងសិក្សារហូតប្រឡងជាប់សញ្ញាប័ត្រទុតិយភូមិដោយជោគជ័យនៅឆ្នាំ២០០២ ហើយបន្តពីនេះទៅមុខទៀតសារ៉ាត់គ្មានរំពឹងថានឹងបានបន្តការសិក្សាបន្ថែមទៀតឡើយពីព្រោះគ្មានប្រាក់ម្យ៉ាងទៀតឪពុកម្តាយកាន់តែចាស់ជរា ។ ជាមួយនឹងភាពអល់អែកគ្មានកោះត្រើយនៅក្នុងជីវិតយុវជនសារ៉ាត់មិនបានបោះបង់ពេលទំនេររបស់ខ្លួនឡើយគេបានចាប់យកមុខរបរធ្វើកូនជ្រូកដែលផលិតអំពីដីសំរាប់លក់ និងនៅសល់ពេលវេលាខ្លះទៀតសារ៉ាត់បានចេញទៅរើសអេតចាយដើម្បីបង្គ្រប់ជីវភាពប្រចាំថ្ងៃ ។

នៅឆ្នាំ២០០២ក្តីសង្ឃឹមបានរះឡើងជាថ្មីម្តងទៀតខណៈពេលដែលក្មួយប្រុសសារ៉ាត់បាននាំប្រធានអង្គការភាពញញឹមនៃកុមារទៅជួបសារ៉ាត់នៅផ្ទះដ៏កំសត់សាងសង់នៅលើត្រពាំងទឹកក្នុងសហគមន៏ជនក្រីក្រដែលស្ថិតនៅក្នុងសង្កាត់ស្ទឹងមានជ័យហើយអ្វីដែលធ្វើអោយសារ៉ាត់រីករាយរំភើបនោះគឺការយល់ព្រមទទួលអោយចូលសិក្សាបណ្តុះបណ្តាលវិជ្ជាជីវៈពីអង្គការភាពញញឹមនៃកុមារដែលមានសប្បុរសជនជាជនជាតិបារាំងជួយឧបត្ថម្ភគាំទ្រដល់កុមារក្រីក្រកម្ពុជា ។ យុវជនសារ៉ាត់បានចាប់



*យុវជន ឯម សារ៉ាត់ កំពុងបំពេញតួនាទីជូនអ្នកដំណើរជាមួយទឹកមុខរួសរាយរាក់ទាក់*

យកការបណ្តុះបណ្តាលជំនាញផ្នែកលេខាធិការនិងរដ្ឋបាលដោយផ្អែកទៅលើលទ្ធផលខ្ពស់នៃការប្រឡងសាកល្បងដែលមានគ្រូស្ម័គ្រចិត្តខ្មែរនិងបារាំងជាអ្នកផ្តល់ប្រឹក្សាម្យ៉ាងទៀតនៅទីនោះសារ៉ាត់បានទទួលអាហាររូបត្ថម្ភមានដូចជាៈ អាហារ ប្រដាប់ប្រដាសិក្សា សំលៀកបំពាក់សំរាប់រយៈពេល ៣ឆ្នាំ ។ ដោយឡែកនៅក្រោយការបណ្តុះបណ្តាលបានបញ្ចប់នៅឆ្នាំ ២០០៥ យុវជនសារ៉ាត់បានដាក់ពាក្យសុំចូលបំរើការងារនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញហើយជាភ័ព្វសំណាងម្តងទៀតសំរាប់យុវជនសារ៉ាត់ដែលត្រូវបានជ្រើសរើសជាបុគ្គលិកសេវាកម្មចុះបញ្ជី និងបែបបទចេញដំណើរជូនភ្ញៀវ(Check-in)នៅឆ្នាំ ២០០៥។ សារ៉ាត់បានរៀបរាប់ទាំងទឹកមុខស្រស់ស្រាយបន្តថាៈដោយសារតែធ្លាប់បានបំពេញកម្មសិក្សានៅតាមក្រុមហ៊ុនមួយចំនួនមានក្រុមហ៊ុនទេសចរណ៍ Diethelm Travel បន្ទាប់មកក្រុមហ៊ុន Design Group និងចុងក្រោយនៅក្រុមហ៊ុន SOFRECO សារ៉ាត់ងាយយល់ពីការងារបានឆាប់រហ័សដោយផ្អែកទៅលើបទពិសោធន៍ខ្លះៗកន្លងមក និងតាមរយៈការបណ្តុះបណ្តាលជំនាញតំបូងនៅអាកាសយានដ្ឋានក៏ប៉ុន្តែការងារទាំងអស់នេះបើគ្មានការព្យាយាមទេវាប្រាកដជាជួបការលំបាកយ៉ាងពិតប្រាកដដូចជានាពេលបច្ចុប្បន្ននេះប្រព័ន្ធពតិមានវិទ្យាថ្មីៗបានត្រូវបំពាក់អោយដំណើរការនៅក្នុងផ្នែកសេវាកម្មចុះបញ្ជីនិងបំពេញបែបបទជូនអ្នក



*ទោះជាមានភារកិច្ចជាច្រើនយ៉ាងណាក៏ ឯម សារ៉ាត បានបំពេញដោយភាពស្មោះស្ម័គ្រ*

ដំណើរហើយប្រព័ន្ធទាំងនេះវាត្រូវសំរបសំរួលទៅតាមតំរូវការរបស់ក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិនិមួយៗម្យ៉ាងទៀតការបណ្តុះបណ្តាលត្រូវធ្វើឡើងទៅតាមដំណាក់កាលរបស់ក្រុមហ៊ុនអាកាសចរណ៍និមួយៗហេតុនេះហើយទើបបុគ្គលិកអាកាសយានដ្ឋានត្រូវខិតខំសំរបសំរួលការងារជាមួយប្រព័ន្ធបច្ចេកវិទ្យាថ្មីៗទាំងនេះក៏ប៉ុន្តែទោះជាយ៉ាងណាក៏វានៅមានការខ្វះខាតដោយអន្លើដោយសារតែមានការរអាក់រអួលផ្នែកបច្ចេកទេសបន្តិចបន្តួចកត្តាសំខាន់នោះយើងត្រូវចេះជួយគ្នាទៅវិញទៅមកគ្រប់មធ្យោបាយទាំងអស់ដើម្បីធ្វើយ៉ាងណាកុំអោយភ្ញៀវអ្នកដំណើររបស់យើងខកខានការហោះហើរ ។ជាការពិតណាស់សារាំត់ក៏មិនភ្លេចរៀបរាប់ពីអារម្មណ៍នៅក្នុងពេលបំពេញការងារដែលតែងជួបនឹងហេតុការណ៍ខ្លះៗបណ្តាលមកពីការរំខានបន្តិចបន្តួចពីភ្ញៀវអ្នកដំណើរជួនពេលខ្លះកើតឡើងពីការមិនយល់ពីកាតព្វកិច្ចរបស់យើងបានធ្វើអោយពួកគាត់មួរហ្មងចំពោះពួកយើងតែទោះជាយ៉ាងណាសារ៉ាត់បានធ្វើការអះអាងថាយើងតែងធ្វើការសំរបសំរួលរឺការសុំអភ័យទោសរួមជាមួយនឹងអារម្មណ៍អត់ធ្មត់ដែលជាជំនាញវិជ្ជាជិវៈនិងក្រមសិលធមិនៃសេវាកម្មអ្នកដំណើរនៅអាកាសយានដ្ឋាន ។

នៅក្នុងឱកាសនេះដែរយុវជនសារ៉ាត់បានសំដែងមោទនភាពផ្ទាល់ខ្លួនចំពោះការងារសេវាកម្មនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញដែលគ្រប់គ្រងដោយក្រុមហ៊ុន SCA/CAMS ដែលបានផ្តល់លក្ខខ័ណ្ឌការងារសមស្របមានដូចជា : ការគាំពារសុខភាព បណ្តុះបណ្តាលលើមុខជំនាញ...លនិងល ។

ជាពិសេសយុវជនសារ៉ាត់មានការសប្បាយរីករាយដោយក្រុមគ្រួសារនាពេលបច្ចុប្បន្ននេះមានកន្លែងស្នាក់នៅសមរម្យឯក្រុងតាខ្មៅមិនដូចពីពេលមុនទៀតទេម្យ៉ាងទៀតជីវភាពប្រចាំថ្ងៃក៏មានសភាពធូរស្រាលជាមធ្យមដែលមិនបង្ករការភ័យព្រួយចំពោះអាណាព្យាបាលជរាទាំងពីរនាក់ ។

***ធនធានមនុស្ស***

## បោះឆ្នោតជ្រើសរើសប្រតិភូតំណាងបុគ្គលិកអាកាសយានដ្ឋានលើកទី៣.....

ក្រុមហ៊ុនសម្បទានព្រលានយន្តហោះ SCA / CAMS បានរៀបចំការបោះឆ្នោតជ្រើសរើសប្រតិភូតំណាងបុគ្គលិកសំរាប់អាណត្តិទី ៣ កាលពីថ្ងៃទី ៣០ ខែធ្នូ ឆ្នាំ ២០០៩ កន្លងទៅនេះនៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងសៀមរាបស្របតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ។ក្រុមហ៊ុនបានគោរព និងអនុវត្តយ៉ាងហ្មឹងហ្មត់ស្ដីពីច្បាប់ការងារដោយពុំដែលអាក់ខានក្នុងការរៀបចំការបោះឆ្នោតដែលជាផ្នែកមួយដ៏សំខាន់ក្នុងកិច្ចសហប្រតិបត្តិការការងារនៅនឹងកន្លែងប្រកបដោយការយោគយល់គ្នាទៅវិញទៅមករវាងថ្នាក់ដឹកនាំក្រុមហ៊ុននិងបុគ្គលិកអាកាសយានដ្ឋាន។ ឆ្លងតាមរយៈការបោះឆ្នោតកន្លងមកនេះអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានជ្រើសរើសបេក្ខជននិងបេក្ខនារីចំនួន ១០ នាក់ស្ថិតនៅក្នុងគណៈទី១( ប្រតិភូតំណាងអោយបុគ្គលិក)ចំណែកឯបេក្ខជននិងបេក្ខនារី ៦នាក់ទៀតស្ថិតនៅក្នុងគណៈទី២ ( ប្រតិភូតំណាងឱ្យបុគ្គលិកបច្ចេកទេសនិងថ្នាក់ដឹកនាំ) ។

ចំណែកឯអាកាសយានដ្ឋានអន្តរជាតិសៀមរាបមានបេក្ខជន និង បេក្ខនារីចំនួន ៨ នាក់ ( ប្រតិភូតំណាងអោយបុគ្គលិក) និងបេក្ខជននិងបេក្ខនារីចំនួន៤នាក់ ( ប្រតិភូតំណាងអោយបុគ្គលិកបច្ចេកទេសនិងថ្នាក់ដឹកនាំ) ។សក្ខីភាពទាំងអស់ខាងលើនេះគឺជាលទ្ធផលដែលបានស្តែងចេញពីឆន្ទះរបស់បុគ្គលិកក្នុងការជ្រើសរើសតំណាងរបស់ខ្លួនក្នុងគោលបំណងការពារផលប្រយោជន៏សមស្របជួយសំរបសំរួលបន្ទុកនានារវាងថ្នាក់ដឹកនាំនិងបុគ្គលិកទាំងអស់ដោយសន្តិវិធីនិងដំណោះស្រាយ ឈ្នះ ឈ្នះ ជាមូលដ្ឋាន។ ឆ្លៀតក្នុងឱកាសចូលរួមបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួននោះយើងបានជួបជាមួយបុគ្គលិកចំនួន៣រូបដើម្បីដកចង់ដឹងពីទស្សនៈរបស់ពួកគាត់ដូចខាងក្រោមនេះ:



*បុគ្គលិកអាកាសយានដ្ឋានអន្តរជាតិភ្នំពេញរីករាយសំដែងឆន្ទះដើម្បីជ្រើសរើសតំណាងរបស់ខ្លួន*

កញ្ញា សារុន សុភាព ជាបុគ្គលិកបំពេញការងារនៅការិយាល័យរដ្ឋបាលនៃក្រុមការងារបច្ចេកទេសផ្ទៃដីអាកាសយានដ្ឋានអន្តរជាតិភ្នំពេញមានមតិថាៈនាងមានអារម្មណ៍រីករាយណាស់នៅក្នុងខណៈដែលរូបនាងបានបោះឆ្នោតជ្រើសរើសតំណាងរបស់ខ្លួនស្របតាមលទ្ធិប្រជាធិបតេយ្យនិងយុត្តិធមិត្រឹមត្រូវហើយនាងសង្ឃឹមថាតំណាងនៅក្នុងអាណត្តិថ្មីនេះនឹងខិតខំបំពេញការងាររបស់ខ្លួនប្រកបដោយជោគជ័យ ។

ចំណែកលោក កែវ ដារិន ជាជំនួយការនាយកផ្នែករោងជាងបានមានប្រសាសន៏ថាៈលោកមានសេចក្តីរីករាយណាស់ដែលលោកបានបំពេញកាតព្វកិច្ចនៅក្នុងការ

ជ្រើសរើសតំណាងរបស់ខ្លួនប្រកបដោយតម្លាភាពនិងប្រជាធិបតេយ្យ។ លោកសង្ឃឹមថាការជ្រើសរើសតំណាងប្រតិភូបុគ្គលិកតាមរយៈសន្លឹកឆ្នោតនេះនឹងនាំមកនូវភាពជិតស្និទ្ធិមួយកំរិតទៀតរវាងថ្នាក់ដឹកនាំនិងបុគ្គលិក។

ចំណែកលោកទេពរិទ្ធីប្រធានទទួលបន្ទុកផ្នែកប្រព័ន្ធព័ត៌មាននៃការិយាល័យផ្នែកធនធានមនុស្សបានអោយដឹងថា១នេះជាលើកដំបូងហើយដែល លោកបានចូលរួមបោះឆ្នោតជ្រើសរើសប្រតិភូបុគ្គលិកនៅក្នុងអាកាសយានដ្ឋានប្រកបដោយភាពត្រឹមត្រូវ ហើយតំណាងនេះនឹងមានតួនាទីដ៏សំខាន់មួយក្នុងការដោះស្រាយរាល់បញ្ហានានាដែលកើតមាននៅក្នុងសង្គមគ្រួសារអាកាសយានដ្ឋានរបស់យើងនឹងរក្សាទំនាក់ទំនងល្អរវាងថ្នាក់ដឹកនាំនិងបុគ្គលិក។



លោក ហ្សុក វ៉ាម៉ូវ៉ាសាតា កំពុងពិនិត្យគំរោងនៅលើការដ្ឋានជាមួយសហការី

## សេវាថែទាំសុខភាព :ការទទួលខុសត្រូវប្រកបដោយសមត្ថភាព

ចាប់តាំងពីបើកដំណើរការដំបូងនៅឆ្នាំ១៩៩៥ ក្រុមហ៊ុន SCA / CAMS បានផ្តល់នូវសេវាថែទាំសុខភាពដល់បុគ្គលិកនិងក្រុមគ្រួសាររបស់ពួកគេសំរាប់ការថែទាំសុខភាពអោយបានល្អប្រសើរ។

សេវាថែទាំសុខភាពរបស់ក្រុមហ៊ុនបានបំពេញតួនាទីរបស់ខ្លួនតាមបទដ្ឋានយ៉ាងល្អប្រសើរម្យ៉ាងទៀតជាការចាំបាច់សំរាប់ពួកគេម្នាក់១បានបង្ហាញអត្ថន័យទទួលខុសត្រូវ និងជាគុណប្រយោជន៏អោយកាន់តែប្រសើរឡើងនៅក្នុងការរៀបចំចាត់ចែងសេវានេះអោយបានស្ថិតស្ថេរគង់វង្ស។

ដើម្បីនឹងធ្វើការត្រួតពិនិត្យប្រព័ន្ធនេះនិងធានាថានឹងដំណើរការទៅបានរលូននៅក្នុងរយៈពេលវែងអោយបានត្រឹមត្រូវជាមូលដ្ឋាននិងសំរាប់ជាគុណប្រយោជន៏ចំពោះគ្រប់១គ្នាតាមនិតិវិធីយដែលមានភាពជាក់លាក់និងល្អិតល្អន់ដែលបានប្រតិបត្តិតាំងពីឆ្នាំ ២០០២ កន្លងទៅនេះហើយនឹងត្រូវកែតំរូវចំណុចខ្លះអោយស្របទៅនឹងបទដ្ឋាន ISOនៅក្នុងរយៈពេលដ៏ខ្លីខាងមុខនេះ។



លោកវេជ្ជបណ្ឌិតពិនិត្យព្យាបាល និងផ្តល់ថ្នាំដល់បុគ្គលិកអាកាសយានដ្ឋាន

នៅក្នុងខណៈពេលដែលអាគាររដ្ឋបាលថ្មីបានបើកដំណើរការកាលពីខែមករាកន្លងទៅនេះបន្ទប់ពិនិត្យពិគ្រោះជំងឺត្រូវបានផ្លាស់ទៅកាន់ទីនោះរួមជាមួយនឹងឧបករណ៏វេជ្ជសាស្ត្រប្រកបដោយផាសុកភាពសំរាប់អ្នកជំងឺ។បន្ទប់ពិនិត្យនិងពិគ្រោះជំងឺនេះបើកបំរើសេវាជារៀងរាល់ថ្ងៃៈ ពេលព្រឹកចាប់ពីម៉ោង ៩ ដល់ម៉ោង ១១ និង ៣០នាទី និងចាប់ពីម៉ោង ១៤ រហូតដល់ម៉ោង ១៦ ល្ងាច សំរាប់ពិនិត្យព្យាបាលជូនដល់បុគ្គលិកអាកាសយានដ្ឋានទាំងអស់ក៏ដូចជាក្រុមគ្រួសាររបស់ពួកគេដែរ។

***សំណួរ និង ចំលើយ***

## ទស្សនៈលោក ហ្សុក វ៉ាម៉ូវ៉ាសាតា

លោកហ្សុកវ៉ាម៉ូវ៉ាសាតាជានាយកគ្រប់គ្រងបច្ចេកទេសដែលទើបមកកាន់តួនាទីនេះកាលពីពេលថ្មី១នេះដែលជានាយកដ្ឋានមួយគ្របដណ្តប់ការងារយ៉ាងធំទូលាយនៅអាកាសយានដ្ឋានមានដូចជាការងារវិស្វកម្មស៊ីវិល អាគារ និងផ្គត់ផ្គង់សំភារៈ។ លោកមានភាពសាមញ្ញ រួសរាយ រាក់ទាក់ សកម្មបំពេញការងារបច្ចេកទេស និងនិយមកីឡាវាយកូនគោល ។

*សំណួរ ( លោក ខែក នរិន្ទដា ) : លោក ហ្សុក តើលោកអាចអាចរៀបរាប់ពីដំណើរជីវិតរបស់លោកនៅមុនពេលដែលមកកាន់ប្រទេសកម្ពុជា និងការងារនៅតាមបណ្តាអាកាសយានដ្ឋានដ៏ទៃ១ទៀត?*

ចំលើយ ( លោក ហ្សុក វ៉ាម៉ូវ៉ាសាតា ): ខ្ញុំមានកំណើតនៅប្រទេសម៉ាដាហ្គាស្កា ( កោះមួយដែលស្ថិតនៅទិសអាគ្នេយ៏នៃចុងជ្រោយនៃទ្វីបអាហ្វ្រិក)។ ខ្ញុំបានចាប់ផ្តើមធ្វើការងារដំបូងតាំងពីយុវវ័យមកម្ល៉េះ ( អាយុ១៧ឆ្នាំ) ហើយខ្ញុំបានចុះឈ្មោះចូលបំរើក្នុងកងទ័ពបារាំងដែលមានមូលដ្ឋាននៅប្រទេសអាល្លឺម៉ង់។ បទពិសោធន៏រយៈពេល៥ឆ្នាំចុងក្រោយនេះបានធ្វើអោយខ្ញុំចូលសិក្សាជាបន្តទៀត។

*សំណួរ : តើលោកសិក្សាអំពីជំនាញអ្វីខ្លះ?*

ចំលើយ : ខ្ញុំមានបញ្ញាផ្នែកវិទ្យាសាស្ត្រហើយជារឿយ១ខ្ញុំតែងតែមានចំណាប់អារម្មណ៏ជាខ្លាំងទៅលើបញ្ហាបច្ចេកទេសនិងមានចំងល់ថាតើទាំងអស់នេះវាដំណើរការទៅយ៉ាងដូចម្តេចដូចជាៈ ម៉ាស៊ីនរថយន្តអំពូលភ្លើង...លនិងល។ ខ្ញុំចង់ក្លាយខ្លួនជាវិស្វករហើយបានចូលសិក្សាអំពីវ៉ែនៅសាលា Douaiនៅប្រទេសបារាំង។

*សំណួរ :ចុះបន្ទាប់ពីបានបញ្ចប់ការសិក្សា ?*

ចំលើយ : ខ្ញុំបានចូលធ្វើការនៅ CGE ដែលជានាយកដ្ឋានសំណង់មួយដែលក្រោយបន្តិច មកបានក្លាយជាក្រុមហ៊ុន វាំងស៊ី ( ដែលជាម្ចាស់ភាគហ៊ុនក្រុមហ៊ុន SCA/CAMS)និងអនុវត្តការងារគំរោងសាងសង់ផ្លូវចរាចរក្រោមដីនៅទីក្រុងម៉ាកសី ( ខាងត្បូងប្រទេសបារាំង ) ។ ខ្ញុំបានចូលរួមនៅក្នុងផ្នែកមួយនៃក្រុមហ៊ុនដែលបានសាងសង់ផ្លូវចរាចរបង់ប្រាក់រយៈពេល៥ឆ្នាំ។អស់រយៈពេលជាច្រើនឆ្នាំដែលបានបំពេញការងារសំណង់ពាណិជ្ជកម្មហើយខ្ញុំមានភាពឈ្លាសវៃក្នុងការរកឃើញពីបច្ចេកទេសថ្មី១នៅតាមបណ្តាការដ្ឋានជាច្រើន។ ខ្ញុំក៏បានបំពេញការងារនៅក្នុងក្រុមហ៊ុនទូរស័ព្ទអស់រយៈពេល ៥ ឆ្នាំ រហូតដល់ឆ្នាំ ២០០៣។

បន្ទាប់ពីនោះមកខ្ញុំបានធ្វើសំណើរទៅបំពេញការងារនៅឯប្រទេសកំណើតរបស់ខ្ញុំ( ម៉ាដាហ្គាស្កា) ក្នុងតួនាទីទំនាក់ទំនងនិងជាប្រធានគ្រប់គ្រងថវិកាសំរាប់គំរោងអភិវឌ្ឍន៏ហេដ្ឋារចនាសម្ព័ន្ធ។

*សំណួរ : លោកបានស្នាក់នៅក្នុងប្រទេសកម្ពុជាអស់រយៈពេល៦ខែកន្លងមកហើយ តើលោកអាចរៀបរាប់អំពីអ្វីដែលជាបទពិសោធន៏ថ្មីនៅទីនេះ?*

ចំលើយ : ខ្ញុំមានសេចក្តីរីករាយហើយខ្ញុំពិតជាចង់បានការស្វែងយល់ពីតំបន់អាស៊ីនិងប្រទេសកម្ពុជាដែលជាទីកន្លែងដែលខ្ញុំបានផ្តើមការងារនៅទីនេះ។

ទី២ : ខ្ញុំសូមធ្វើការកំណត់បង្ហាញនៅក្នុងការងារបច្ចេកទេសថ្មី១ដែលជាគោលបំណងនៃសំណើរការងារមកកាន់អាកាសយានដ្ឋានកម្ពុជា។ខ្ញុំបានយល់ដឹងពីការអនុវត្តការងារនៅក្នុងឧស្សាហកម្មអាកាសយានដ្ឋានដែលជាការបណ្តុះបណ្តាលបទពិសោធន៏ហើយវាតែងមានការផ្លាស់ប្តូរជាប្រចាំ។កំរិតនៃប្រតិបត្តិការវាមានទំហំធំទូលាយហើយទីតាំងការងារក៏មានភាពល្អប្រសើរផងដែរ។

*សំណួរៈតើលោកចង់បានលទ្ធផលបែបណានៅក្នុងប៉ុន្មានខែខាងមុខនេះ?*

ចំលើយៈខ្ញុំសូមធ្វើការបង្ហាញពីរបៀបថ្មីមួយនាយកដ្ឋានបច្ចេកទេសបានបំពេញការងារជាអ្នកមានបុព្វសិទ្ធិក្នុងការផ្គត់ផ្គង់សំរាប់នាយកដ្ឋាន និងការិយាល័យទាំងអស់នៅអាកាសយានដ្ឋានដែលជាភ្ញៀវរបស់យើង។ បានន័យថាយើងបានណែនាំចំពោះពួកគេពីទំរង់គំរោងបច្ចេកទេសដែលពួកគេបានចាប់ផ្តើមការងារ។ ដូច្នេះក្នុងន័យនេះយើងអាចសន្សំថាមពល និងថវិកាដែលជាបំណងនៃជំរើសដ៏ប្រសើរ។ មិនត្រឹមតែប៉ុណ្ណោះខ្ញុំចង់បើកចំហរនាយកដ្ឋានរបស់ខ្ញុំដូចនេះគ្រប់១គ្នាត្រូវតែបញ្ចេញសម្បជញ្ញៈសំរាប់គំរោងរបស់យើង។

យើងកំពុងបំពេញប្រតិបត្តិការសាងសង់ជាច្រើនហើយយើងមានទំនាក់ទំនងរឿងនេះ។មិនត្រឹមតែប៉ុណ្ណោះខ្ញុំបានស្នើទៅបុគ្គលិកនៅក្នុងនាយកដ្ឋានរបស់ខ្ញុំអោយសកម្មក្នុងការសរសេររឿងរ៉ាវផ្សេង១សំរាប់ការចុះផ្សាយក្នុងព្រឹត្តិប័ត្រអាកាសយានដ្ឋាន។ទស្សនកិច្ចនៅលើការដ្ឋានគួរត្រូវបានរៀបចំជាមូលដ្ឋានសំរាប់បុគ្គលិកអាកាសយានដ្ឋានទាំងអស់អោយបានជាប់ប្រចាំ។

ព្រឹត្តិការណ៍ខ្លីៗពីអាកាសយានដ្ឋាន

# ព័ត៌មានសង្ខេបប្រចាំខែ



យន្តហោះនៃក្រុមហ៊ុនអាកាសចរណ៍ចិនបានឈប់សំចតនៅពាក់កណ្តាលអាធ្រាតក្នុងឱកាសបុណ្យចូលឆ្នាំចិន

១-នៅក្នុងឱកាសនៃពិធីបុណ្យចូលឆ្នាំចិនកន្លងទៅនេះក្រុមហ៊ុនអាកាសចរណ៍ចិនបានបង្កើនសេវាកម្មហោះហើររបស់ខ្លួនយ៉ាងមមាញឹកបើទោះណាជាពិភពលោកកំពុងទទួលរងវិបត្តិសេដ្ឋកិច្ចយ៉ាងណាក៏ដោយមានអ្នកទេសចរកម្ពុជានិងជនជាតិចិនបានធ្វើដំណើរទេសចរទៅកាន់គោលដៅនានាមានដូចជាទីក្រុងហុងកុង គង់ចូវ សៀងហៃ ណានជីង ដែលជាចរន្តទេសចរគួរអោយកត់សំគាល់ហើយពុំធ្លាប់កើតមានកាលពីរដូវចូលឆ្នាំចិននាឆ្នាំកន្លងទៅនេះ ។ ក្នុងនោះគេសង្កេតឃើញភាគច្រើនជាក្រុមហ៊ុនអាកាសចរណ៍ចិនក្នុងនោះមានៈក្រុមហ៊ុនអាកាសចរណ៍ចិន CHINA SOUTHERN, DRAGONAIR, CHINA EASTERN YUNNAN AIRLINES បានបង្កើនសេវាកម្មហោះហើររបស់ខ្លួនជាងបណ្តាក្រុមហ៊ុនអាកាសចរណ៍អន្តរជាតិនានាដែលមានសេវាកម្មហោះហើរមកកាន់ប្រទេសកម្ពុជា ។

២-ដោយឡែកក្រុមហ៊ុនអាកាសចរណ៍ចិន AIR CHINA បានបើកសេវាហោះហើរពាណិជ្ជកម្មដោយត្រង់ជាលក្ខណៈ CHARTER ពីទីក្រុង HANGZHOU មកកាន់រាជធានីភ្នំពេញនាវេលាម៉ោង ១ ទៀបភ្លឺកាលពីថ្ងៃទី ២៧ ខែមករាឆ្នាំ ២០០៩ កន្លងទៅនេះ ។

ក្រុមហ៊ុនអាកាសចរណ៍ AIR CHINA បានប្រើប្រាស់យន្តហោះដឹកអ្នកដំណើរធុនអ៊ែរប៊ូសអា-៣១៩ដែលអាចដឹកអ្នកដំណើរចំនួន ១២៨ នាក់ ក្នុងនោះភាគច្រើនជាអ្នកទេសចរចិនហើយសេវាកម្មនេះនឹងធ្វើការហោះហើរចំនួន ៧ លើកនៅក្នុងរយៈពេលខែកុម្ភៈឆ្នាំ២០០៩ ។

៣-នៅអាកាសយានដ្ឋានអន្តរជាតិសៀមរាបសេវាកម្មហោះហើរជាលក្ខណៈ CHARTER បានលេចឡើងគួរអោយកត់សំគាល់ក្នុងនោះមានក្រុមហ៊ុនអាកាសចរណ៍ Jeju Air ដែលហោះហើរត្រង់មកពីទីក្រុង Cheong Ju (សាធារណរដ្ឋកូរ៉េខាងត្បូង) មកកាន់ខេត្តសៀមរាបរួមជាមួយអ្នកដំណើរទេសចរជនជាតិកូរ៉េចំនួន១៧៣នាក់ ។

ក្រុមហ៊ុនអាកាសចរណ៍នេះបានដំណើរការហោះហើរចំនួន ៧ លើកហើយបានបញ្ចប់សេវាកម្មរបស់ខ្លួននៅក្នុងអំឡុងខែមករាឆ្នាំ២០០៩ កន្លងទៅនេះ ។ ចំណែកការហោះហើរមួយទៀតដែលមានអ្នកទេសចរចំនួន១៧០នាក់ជាជនជាតិតៃវ៉ាន់បានមកដល់ខេត្តសៀមរាបតាមរយៈយន្តហោះដឹកអ្នកដំណើរធុនអ៊ែរប៊ូស អា-៣២១ របស់ក្រុមហ៊ុនអាកាសចរណ៍ TRANS ASIA ដែលហោះហើរមកពីទីក្រុងតៃប៉ិ ។

រហូតមកទល់ពេលនេះសេវាកម្មហោះហើរមួយនេះមានចំនួន១៤លើករួចមកហើយក៏ប៉ុន្តែក្រុមហ៊ុនអាកាសចរណ៍នឹងបន្តសេវាកម្មហោះហើរនេះរហូតដំណាច់ខែកុម្ភៈខាងមុខនេះ ។

៤-ដើម្បីចូលរួមក្នុងការជួយសន្សំ និងកាត់បន្ថយការចំណាយថវិកាទៅលើអ្នកម៉ៅការសំរាប់សេវាបច្ចេកទេសថែទាំម៉ាស៊ីនត្រជាក់នាយកដ្ឋានថែទាំបច្ចេកទេសអាកាសយានដ្ឋានអន្តរជាតិភ្នំពេញបានបង្កើតក្រុម-ការងារមួយកាលពីដើមឆ្នាំ ២០០៩ សំរាប់ថែទាំបច្ចេកទេសម៉ាស៊ីនត្រជាក់ដល់បណ្តានាយកដ្ឋាននិងការិយាល័យនានាមានដូចជាៈ នាយកដ្ឋានបច្ចេកទេសផ្ទៃដី ស្ថានីយសង្គ្រោះនិងពន្លត់អគ្គីភ័យ នាយកដ្ឋានថែទាំបច្ចេកទេស នាយកដ្ឋាន PLATFORM និងស្ថានីយ៍ផ្គត់ផ្គង់ថាមពលអគ្គិសនី ។ ដោយរួមទាំងធ្វើការជួសជុលនិងផ្លាស់ប្តូរអោយបានល្អប្រសើរដូចអ្នកម៉ៅការធ្លាប់បានអនុវត្តកន្លងមក ។

• ទាំងអស់ខាងលើនេះជាសកម្មភាពសេវាកម្មដ៏សំខាន់របស់បុគ្គលិកនៃនាយកដ្ឋានថែទាំបច្ចេកទេសរបស់យើងហើយសូមឆ្លៀតក្នុងឱកាសនេះរំលឹកជូនថាចំពោះសេវាកម្មខាងលើនេះសូមអស់លោកទូរស័ព្ទមកកាន់លេខ ០១២ ៨១៣ ៨១០ រឺ ស្តង់ដា ១៨២៤ ។

• នេះជាការបញ្ជាក់ជូនរបស់លោក នូ គីមនី នាយកគ្រប់គ្រងនាយកដ្ឋានថែទាំបច្ចេកទេស ។

ដំណឹងថ្មី

# អាគាររដ្ឋបាលថ្មីបើកទ្វារដំណើរការ



សមិទ្ធិផលអាគាររដ្ឋបាលថ្មីដែលទើបបានសាងសង់រួចរាល់ជាស្ថាពរ

អាគាររដ្ឋបាលថ្មីមួយកន្លែងរបស់ក្រុមហ៊ុន SCA/CAMS ដែលមានផ្ទៃក្រឡាទំហំប្រមាណ១.០០០ម៉ែត្រក្រឡាបានប្រារព្ធពិធីសូត្រមន្តប្រោះព្រំពរជ័យតាមប្រពៃណីដើម្បីដាក់អោយដំណើរការពីវេលាព្រឹកថ្ងៃទី ២២ ខែមករាឆ្នាំ ២០០៩ កន្លងទៅនេះដោយមានការចូលរួមពីថ្នាក់ដឹកនាំក្រុមហ៊ុននិងបុគ្គលិកដែលបំរើការនៅការិយាល័យរដ្ឋបាល ។

អាគាររដ្ឋបាលថ្មីនេះបានសាងសង់តាំងពីដើម ខែតុលាឆ្នាំ ២០០៨ រហូតថ្ងៃទី ១៥ ខែមករា ឆ្នាំ ២០០៩ ទើបរួចរាល់ជាស្ថាពរ ហើយអាគារនេះនឹងជួយសំរបសំរួលបរិយាកាសការងារប្រកបដោយផាសុកភាពនិងកាន់តែប្រសើរឡើង ។ សំណង់អគាររដ្ឋបាលថ្មីនេះត្រូវបានរ៉ាប់រងសាងសង់ដោយក្រុមហ៊ុនមូហ៊ីបាកម្ពុជាតាមរយៈគំរោងអភិវឌ្ឍរបស់ក្រុមហ៊ុនសម្បទានព្រលានយន្តហោះSCA/CAMS ។

# អាពាហ៍ពិពាហ៍ កំណើត ថ្លែងសរសើរ

**អបអរសាទរចំពោះពិធីអាពាហ៍ពិពាហ៍មង្គលការរវាងគូរស្វាមីភរិយាថ្មីថ្មោង**

**អាកាសយានដ្ឋានអន្តរជាតិភ្នំពេញ :**

ថ្ងៃទី ៣ ខែ វិច្ឆិកា ឆ្នាំ ២០០៨ លោក ផុន សាមឿន (ផ្នែកដឹកជញ្ជូននៃនាយកដ្ឋានបច្ចេកទេសផ្ទៃដី) និង អ្នកនាង អ៊ីន ស្រ៊ន់ (រូបថតទី ១)

**អាកាសយានដ្ឋានអន្តរជាតិសៀមរាប :**

ថ្ងៃទី ១២ ខែ វិច្ឆិកា ឆ្នាំ ២០០៨ លោក ប៉ុល សុផល (សេវាកម្មបែបបទជូនអ្នកដំណើរ) និងអ្នកនាង ស៊ីម ពិសី (បុគ្គលិកប្រមូលកំរៃសេវាកម្មអ្នកដំណើរ) (រូបថតទី ២)




